00398430

**Declassified to Public**

**12 April 2013**

លេខ/ No: D130/11/2

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**BUREAU DES CO-JUGES D'INSTRUCTION**
**OFFICE OF THE CO-INVESTIGATING JUDGES**

ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៩

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 30 / 10 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**ជូន៖** **ក្រុមមេធាវីការពារក្តី នួន ជា និង អៀង សារី**
សុន អរុណ Victor KOPPE, Michiel PESTMAN
អាង ឧត្តម, Michael G. KARNAVAS

**ពី៖** **ចៅក្រម យូ ប៊ុនឡេង**

**ចៅក្រម** Marcel Lemonde
**សហចៅក្រមស៊ើបអង្កេត**

**សម្គាល់**

**កម្មវត្ថុ៖** **សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ១៥ របស់ក្រុមមេធាវីការពារក្តី នួន ជា រួមទាំងលិខិតដែលពាក់ព័ន្ធនានារបស់ក្រុមមេធាវីការពារក្តី អៀង សារី ទាក់ទងនឹង ភស្តុតាងដែលទទួលបានដោយអំពើទារុណកម្ម**

**យោង៖** ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស-D130/11
០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស-D130/7
០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស-D130/7/2

នៅក្នុងសំណើសុំរបស់ក្រុមមេធាវីការពារក្តី នួន ជា ចុះថ្ងៃ ០១ កញ្ញា ២០០៩ ក្រុមមេធាវីការពារក្តីបានស្នើឲ្យសហចៅក្រមស៊ើបអង្កេត បំពេញនូវកិច្ចស៊ើបសួរដូចខាងក្រោម៖

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de réception): 30 / 10 / 2009
ម៉ោង (Time/Heure): 11:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

00398431



*"(ក). កំណត់ឱ្យបានច្បាស់ចំពោះភស្តុតាងណាមួយ និងទាំងអស់ដែលប្រឡាក់ប្រឡូកដោយការធ្វើទារុណកម្ម ដែលខ្លួនយកមកសំអាង (រួមទាំងឯកសារដែលមាននៅក្នុង SMD) ក្នុងការចង្អុលបង្ហាញពីការចោទប្រកាន់របស់ ក.ស.ព. ប្រឆាំងមកលើរូបលោក នួន ជា សម្រាប់ការស្វែងរកការពិតរបស់ខ្លួន ឬសម្រាប់គោលបំណងផ្សេងពីនេះ។*

*(ខ). កំណត់ឱ្យបានច្បាស់ចំពោះភស្តុតាងណាមួយ និងទាំងអស់ដែលប្រឡាក់ប្រឡូកដោយការធ្វើទារុណកម្ម ដែលខ្លួនយកមកសំអាង (រួមទាំងឯកសារដែលមាននៅក្នុង SMD) ដែលត្រូវបានពិចារណាសម្រាប់គោលបំណងដែលបានលើកឡើងខាងលើនេះ តែត្រូវបានច្រានចោលភ្លាមៗ និង*

*(គ). នៅក្នុងករណីនីមួយៗ បង្ហាញឱ្យបានច្បាស់លាស់ពីវិធីសាស្ត្រត្រឹមត្រូវ ដែលបានយកមកប្រើប្រាស់ក្នុងការសម្រេចទៅលើតម្លៃខាងបច្ចេកវិទ្យានៃភស្តុតាង ដែលប្រឡាក់ប្រឡូកដោយការធ្វើទារុណកម្ម[1]"*។

ក្រុមមេធាវីការពារក្តី នួន ជា បានបន្ថែមទៀតថាខ្លួន *"សូមចូលរួម និងយកតាមសំណើសុំរបស់អៀង សារី និងជម្រុញឱ្យ ក.ស.ច.ស. ធ្វើតាមសំណូមពរដែលបានស្នើសុំនៅក្នុងសំណើនេះឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន[2]"*។ សំណើសុំរបស់ អៀង សារី ដែលចុះថ្ងៃ ១៧ កក្កដា ២០០៩ និងដែលខ្លឹមសាររបស់វាត្រូវបានលើកឡើងជាថ្មីម្តងទៀត នៅក្នុងលិខិតមួយទៀតដែលចុះថ្ងៃ ០៧ សីហា ២០០៩ បានស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតផ្តល់នូវព័ត៌មានដូចខាងក្រោម៖

*"១. ថាតើដល់កំរិតណាហើយដែល ក.ស.ច.ស. បានទទួលស្គាល់យ៉ាងច្បាស់លាស់ នូវភស្តុតាងដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលរួមបញ្ចូលនូវភស្តុតាងដែលទទួលបានមកពីការធ្វើទារុណកម្ម។ ក្នុងចំណោមអ្វីផ្សេងទៀត ដីកានេះមានរួមបញ្ចូលនូវរបាយការណ៍នានា*

---

[1] D130/11 សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ១៥ របស់ក្រុមមេធាវីការពារក្តី នួន ជា ថ្ងៃ ០១ កញ្ញា ២០០៩ កថាខណ្ឌ ០៧។

[2] ដូចយោងខាងលើ



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

00398432

លេខ/ No: D130/11/2

*ឬការវិភាគទាំងឡាយដែលយកជាសំអាង ឬបង្កើតឡើងដោយ ក.ស.ព. ដែលមានផ្ទុកនូវព័ត៌មាន ដែលទទួលបានដោយការធ្វើទារុណកម្ម។*

*២. ថាតើដល់កំរិតណាហើយដែល ក.ស.ច.ស. បានទទួលស្គាល់យ៉ាងច្បាស់លាស់ នូវភស្តុតាងដែលកើតចេញពីព័ត៌មានដែលទទួលបានពីការធ្វើទារុណកម្ម"។*

*៣. ថាតើដល់កំរិតណាហើយដែល ក.ស.ច.ស. បានកំណត់នូវបទដ្ឋានស្តីពីអ្វីដែលបង្កើតបានជាព័ត៌មានដែលទទួលបានដោយការធ្វើទារុណកម្ម។*

*៤. ថាតើដល់កំរិតណាហើយដែល ក.ស.ច.ស. បានបង្កើតនូវសេចក្តីណែនាំស្តីពីការប្រើប្រាស់នូវព័ត៌មានដែលទទួលបានពីការធ្វើទារុណកម្ម។*

*៥. ថាតើដល់កំរិតណាហើយដែល ក.ស.ច.ស. បានប្រើប្រាស់ព័ត៌មានដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ដើម្បីជាមធ្យោបាយដើម្បីប្រមូលព័ត៌មានបន្ថែមទៀត។*

*៦. ថាតើដល់កំរិតណាហើយដែល ក.ស.ច.ស. មានចេតនាដើម្បីលាតត្រដាងដល់ជនត្រូវចោទនូវព័ត៌មានដែលខ្លួនមាន ដែល ក.ស.ច.ស. ជឿជាក់ថាព័ត៌មានមាននោះ គឺជាលទ្ធផលនៃការធ្វើទារុណកម្ម ឬដែលកើតចេញពីការធ្វើទារុណកម្ម[3]"។*

ដូចដែលបានលើកឡើងដោយក្រុមមេធាវីការពារក្តី អៀង សារី នៅក្នុងសំណើសុំលើកទី ០២ របស់ខ្លួន ផ្នែកមួយចំនួននៃសំណើសុំ លើកទី ០១ របស់ពួកគេមានការទាក់ទងជាមួយនឹងសំណើសុំលើកទី ០៣ ដូច្នេះចម្លើយតបនានាចំពោះបញ្ហាទាំងនេះ ជាកម្មវត្ថុនៃចម្លើយតបដាច់ដោយឡែកមួយ។ រីឯចម្លើយតបចំពោះសំណើសុំរបស់ក្រុមមេធាវីការពារក្តី នួន ជា ក៏ត្រូវធ្វើដូច្នេះដែរ[4]។ ជាងនេះទៅ

---

[3] D130/7 លិខិតរបស់ក្រុមមេធាវីការពារក្តី អៀង សារី ទាក់ទងនឹងការទទួលស្គាល់ និងការសំអាងទៅលើភស្តុតាង ដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ចុះថ្ងៃ ១៧ កក្កដា ២០០៩។ D130/7/2 លិខិតលើកទី ០២ របស់ក្រុមមេធាវីការពារក្តី អៀង សារី ទាក់ទងនឹងការទទួលស្គាល់ និងការសំអាងទៅលើភស្តុតាង ដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ចុះថ្ងៃ ៧ សីហា ២០០៩។

[4] D130/7/2 លិខិតលើកទី ០២ របស់ក្រុមមេធាវីការពារក្តី អៀង សារី ទាក់ទងនឹងការទទួលស្គាល់ និង ការ សំអាង ទៅលើភស្តុតាង ដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ចុះថ្ងៃ ៧ សីហា ២០០៩។ D130/11 សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ១៥ របស់ក្រុមមេធាវីការពារក្តី នួន ជា ថ្ងៃ ០១ កញ្ញា ២០០៩ កថាខណ្ឌ ០៧ (គ)



CO-INVESTIGATING JUDGES * ECCC * CIJ

00398433



ទៀត ដូចដែលក្រុមមេធាវីការពារក្តី នួន ជា បានលើកឡើងនៅក្នុងសំណើសុំរបស់ខ្លួនហើយថា ដីកាសម្រេចទាក់ទងនឹងការប្រើប្រាស់ភស្តុតាងដែលទទួលបានដោយអំពើទារុណកម្ម[5] កំពុងជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ហេតុដូចនេះចម្លើយតបនានាចំពោះសំណើសុំបែបនេះ ហាក់ដូចជាមានលក្ខណៈឆាប់រហ័សមុនកាលវេលាពេក។

ទោះបីជាយ៉ាងណាក៏ដោយ ដោយហេតុថារហូតមកដល់ពេលនេះ មិនទាន់មានការសម្រេចលើបណ្តឹងឧទ្ធរណ៍ខាងលើ យើងបានសម្រេចធ្វើការជូនដំណឹងដល់ក្រុមមេធាវីការពារក្តីក្នុងពេលនេះថា លើកលែងចំពោះករណីដែលមានការសម្រេចផ្សេងណាមួយដោយអង្គបុរេជំនុំជម្រះ គឺយើងនៅតែគោរព និងអនុវត្តនូវគោលការណ៍នានា ដែលមានកំណត់នៅក្នុងដីកាសម្រេចរបស់យើងប្រកបដោយតម្លាភាព។

ទោះបីជាបែបនេះក្តី ដូចដែលយើងបានបញ្ជាក់នៅក្នុងដីកាសម្រេចរបស់យើងកាលពីលើកមុនរួចហើយ ការវាយតម្លៃដោយត្រឹមត្រូវលើភស្តុតាងបែបនេះ អាចធ្វើទៅបាន *"បន្ទាប់ពីការបិទកិច្ចស៊ើបសួរតែប៉ុណ្ណោះ គឺនៅពេលដែលសំណុំរឿងពេញលេញគ្រប់គ្រាន់[6]"*។ ក្រុមមេធាវីការពារក្តីអាចនឹងពេញចិត្តចំពោះខ្លឹមសារអត្ថបទនៃដីកាដំណោះស្រាយ នៅពេលណាដែលភស្តុតាងទាំងផ្ទាល់ និងប្រយោលនីមួយៗ ដែលរកឃើញថាមានការពាក់ព័ន្ធជាមួយនឹងការប្រើប្រាស់អំពើទារុណកម្មត្រូវបានវិភាគ និងវាយតម្លៃមួយករណីម្តងៗ បន្ទាប់ពីកិច្ចស៊ើបសួរត្រូវបានបញ្ចប់ តែប៉ុណ្ណោះ។

---

[5] D130/8 ដីកាសម្រេចអំពីការប្រើប្រាស់ភស្តុតាងដែលទទួលបាន ឬអាចនឹងទទួលបានដោយអំពើទារុណកម្ម ចុះថ្ងៃ ២៨ កក្កដា ២០០៩។

[6] ដូចយោងខាងលើ កថាខណ្ឌ ២៨

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION